# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

SOCIAL PROTECTION IN CAMBODIA

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

## សេចក្តីជូនដំណឹង
## ស្តីពី
## ការបើកផ្តល់ប្រាក់ឧបត្ថម្ភជូនបងប្អូនកម្មករនិយោជិតក្នុងវិស័យកាត់ដេរ ដែលត្រូវបានព្យួរកិច្ចសន្យាការងារស្របតាមស្មារតីនៃកញ្ចប់វិធានការរបស់រាជរដ្ឋាភិបាល (លើកទី១៣)

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងដល់បងប្អូនកម្មករនិយោជិតដែលបានព្យួរកិច្ចសន្យាការងារក្នុងខែកញ្ញា ខែតុលា និងខែវិច្ឆិកា ឆ្នាំ២០២៣ នៃរោងចក្រ ទាំង២៨ នៃវិស័យវាយនភណ្ឌ កាត់ដេរ ផលិតស្បែកជើង និងផលិតផលិតផលធ្វើដំណើរនិងកាបូប (ដូចមានភ្ជាប់នៅក្នុងឧបសម្ព័ន្ធ) ដែលទទួលបានការអនុញ្ញាតព្យួរកិច្ចសន្យាការងារស្របតាមស្មារតីនៃសេចក្តីណែនាំលេខ០២០/២៣ ក.ប/ស.ណ.ន.ខ.ល ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២៣ ស្តីពីការព្យួរកិច្ចសន្យាការងារកម្មករនិយោជិតធ្វើការនៅរោងចក្រក្នុងវិស័យវាយនភណ្ឌ កាត់ដេរ ផលិតស្បែកជើង និងផលិតផលិតផលធ្វើដំណើរនិងកាបូប ដែលរងផលប៉ះពាល់ដោយសារវិបត្តិសេដ្ឋកិច្ចសកល ជ្រាបថា ធនាគារ វីង (ខេមបូឌា) ម.ក នឹងផ្ញើសារអំពីការបើកប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាលទៅលេខទូរសព្ទ ដែលបងប្អូនបានផ្តល់មកឱ្យក្រសួងតាមរយៈរដ្ឋបាលរោងចក្រនាពេលកន្លងមក។

ប្រាក់ឧបត្ថម្ភនេះនឹងត្រូវបើកផ្តល់ជាប្រាក់រៀល និងអាស្រ័យលើចំនួនថ្ងៃនៃការព្យួរកិច្ចសន្យាការងារ ក្នុងនោះចំនួន៖

- ៨១ ០០០រៀល (២០ដុល្លារអាម៉េរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ៧ថ្ងៃ ដល់ ១៤ថ្ងៃ
- ១៦២ ០០០រៀល (៤០ដុល្លារអាម៉េរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ១៥ថ្ងៃ ដល់ ១ខែ។

ក្រសួងសូមរំឭកថា ធនាគារ វីង (ខេមបូឌា) ម.ក នឹងបង្វិលប្រាក់ឧបត្ថម្ភនេះជូនរាជរដ្ឋាភិបាលវិញ ប្រសិនជាបងប្អូនខកខាន មិនបានទៅបើកប្រាក់ឧបត្ថម្ភនេះ ក្នុងរយៈពេល ២១ថ្ងៃ បន្ទាប់ពីទទួលបានសារតាមទូរសព្ទពីធនាគារ វីង (ខេមបូឌា) ម.ក។ ដើម្បីបើកប្រាក់ឧបត្ថម្ភនេះ បងប្អូនត្រូវយកអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងទូរសព្ទដែលទទួលបានសារនោះទៅកាន់ភ្នាក់ងារវីងដែលនៅជិតបំផុត។ សូមបញ្ជាក់ថា បងប្អូនមិនតម្រូវឱ្យបង់ថ្លៃសេវាទៅភ្នាក់ងារវីងឡើយពេលបើកប្រាក់ឧបត្ថម្ភនេះ។

ក្នុងករណីបងប្អូនកម្មករនិយោជិត ដែលបម្រើការងារនៅរោងចក្រទាំង២៨ នេះ មិនបានទទួលសារទូរសព្ទពីធនាគារ វីង (ខេមបូឌា) ម.ក នោះសូមបងប្អូនទំនាក់ទំនងសួរព័ត៌មានបន្ថែម ឬធ្វើបច្ចុប្បន្នភាពលេខទូរសព្ទរបស់ខ្លួនទៅរដ្ឋបាលរោងចក្ររបស់ខ្លួន។ ក្រសួងនឹងបន្តជូនដំណឹងដល់បងប្អូនកម្មករនិយោជិតរោងចក្រដទៃផ្សេងទៀត ដែលទទួលបានការអនុញ្ញាតព្យួរកិច្ចសន្យាការងារអំពីការបើកផ្តល់ប្រាក់ឧបត្ថម្ភនេះ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម សាធារណជន ជាពិសេសបងប្អូនកម្មករនិយោជិតជ្រាបជាព័ត៌មាន និងសូមរួសរាន់ទំនាក់ទំនងបើកប្រាក់ឧបត្ថម្ភនេះនៅតាមភ្នាក់ងារវីងនានាដែលនៅជិតបំផុតឱ្យបានទាន់ពេលវេលា។

ថ្ងៃ ខែ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០២៣

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

គណៈកម្មការអនុវត្តវិធានការរាជរដ្ឋាភិបាល

ឧបសម្ព័ន្ធ នៃសេចក្តីជូនដំណឹងចុះថ្ងៃទី៤ ខែ ឆ្នាំ២០២៣

បញ្ជីឈ្មោះ រោងចក្រ ក្នុងវិស័យកាត់ដេរ

ចំនួន ២៨ ដែលទទួលបានប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាល

| ល.រ | ឈ្មោះរោងចក្រ | រាជធានី ខេត្ត |
|---|---|---|
| វិស័យកាត់ដេរ | | 28 |
| 1 | ក្រុមហ៊ុន ឌីន លីង ហ្វាមិន ឯ.ក | ភ្នំពេញ |
| 2 | ក្រុមហ៊ុន អ៊ីភីក អ៊ិនធើណេសិនណល ឯ.ក | ភ្នំពេញ |
| 3 | ក្រុមហ៊ុន ស៊ីផេក ហ្វាមិន (ខេមបូឌា) ឯ.ក | ភ្នំពេញ |
| 4 | ក្រុមហ៊ុន ស៊ីកូ(ភ្នំពេញ)ខូអិលធីឌី | ភ្នំពេញ |
| 5 | ក្រុមហ៊ុន អេ ខេ អិម ហ្គាមេន | ភ្នំពេញ |
| 6 | ក្រុមហ៊ុន ស៊ីន ឡាន (ខេមបូឌា)ហ្គាមេន ខមភេនីលីមីធីត | ភ្នំពេញ |
| 7 | ក្រុមហ៊ុន ជា ជា ហ៊ី ហ្វាមិន (ខេមបូឌា) ឯ.ក | ភ្នំពេញ |
| 8 | ក្រុមហ៊ុន ខ្វាន់ទុម ខ្លូស៊ីង (ខេមបូឌា) លីមីតធីត | ភ្នំពេញ |
| 9 | ក្រុមហ៊ុន មីឈី (ខេមបូឌា) ហ្វាមិន ឯ.ក | ភ្នំពេញ |
| 10 | ក្រុមហ៊ុន អប្សរា ហ្គាមេន ខូអិលធីឌី | ភ្នំពេញ |
| 11 | ក្រុមហ៊ុន ញូអេសថ៍ ហ្វាមិន (ខេមបូឌា)ឯ.ក | ភ្នំពេញ |
| 12 | ក្រុមហ៊ុន ហ៊ុង យៀក អេនធើប្រាយ ឯ.ក | ភ្នំពេញ |
| 13 | ក្រុមហ៊ុន ប៊ី ឌី (ខេមបូឌា) ស្ពត | ភ្នំពេញ |
| 14 | ក្រុមហ៊ុន ហ្គែននី វីន ប៉ែក (ខេមបូឌា) ឯ.ក | កណ្តាល |
| 15 | ក្រុមហ៊ុន ហ្គ្រេត ហ្វេសិន (ខេមបូឌា) ឯ.ក | កណ្តាល |
| 16 | ក្រុមហ៊ុន សាន់ហ្គ្រេស ស្ព័ត(ខេមបូឌា) ខូអិលធីឌី | កណ្តាល |
| 17 | ក្រុមហ៊ុន ប្លាញតិច (ខេមបូឌា) ឯ.ក | កំពង់ស្ពឺ |
| 18 | ក្រុមហ៊ុន ស៊ីគ្គូ (ខេមបូឌា)ឯ.ក | កំពង់ស្ពឺ |
| 19 | ក្រុមហ៊ុន ស៊ីអិនឌីហ្វ្រី អិនធើណេសិនណល (ខេអេច) ឯ.ក | កំពង់ស្ពឺ |
| 20 | ក្រុមហ៊ុន ថិចសាន់(ខេមបូឌា)នីតធីង វ៉ស៊ីង ដាយអ៊ីង អេន ព្រីនធីង ឯ.ក | កំពង់ស្ពឺ |
| 21 | ក្រុមហ៊ុន ហេង ស៊ីម ហ្វ៊ូត វែរ ឯ.ក | កំពង់ស្ពឺ |
| 22 | ក្រុមហ៊ុន ស៊ុន ខេង ហ្គាមេន(ខេបូឌា)ខូអិលធីឌី | កំពង់ស្ពឺ |
| 23 | ក្រុមហ៊ុន សាន់វ៉ាយ ហ្វេសិន(ខេមបូឌា)ឯ.ក | កំពង់ស្ពឺ |

| ល.រ | ឈ្មោះរោងចក្រ | រាជធានី ខេត្ត |
|---|---|---|
| 24 | ក្រុមហ៊ុន ស្មាតស៊ើតស៍ ហ្គាមេន មេនូហ្វេកធើរីង (ខេមបូឌា) | កំពង់ស្ពឺ |
| 25 | ក្រុមហ៊ុន វីនក្រោន (ខេមបូឌា) អិនដាសស្ទ្រៀល ឯ ក | កំពង់ស្ពឺ |
| 26 | ក្រុមហ៊ុន ស៊ីអេសហ្គោលវេ ថេកស្តាយ (ខេមបូឌា)ខូអិលធីឌី | តាកែវ |
| 27 | ក្រុមហ៊ុន ឡុង ឈឹង ស៊ូ ផាត ឯ.ក | កំពង់ចាម |
| 28 | ក្រុមហ៊ុន ធី.ខេ ហ្គាមេន ស៊ីសុផុន | បន្ទាយមានជ័យ |